**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤២០ ស.ស.រ

# សេចក្តីសំរេច

## ស្តីពីការព្យួរការងារមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / រកម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងមន្ត្រីរាជការ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**ប្រការ ១** : ត្រូវបានព្យួរការងារមន្ត្រីរាជការពីររូប ដែលបានប្រព្រឹត្តខុសក្នុងជំពូកទី ០៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលតាមការកំណត់ដូចខាងក្រោម :

www.pheakdeylaw.com

ក- លោក អ៊ុី **ទិចិត្រ** បច្ចុប្បន្នជាប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងសុខាភិបាល ត្រូវព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៦ ខែ ដោយគិតចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ និងផ្លាស់អោយទៅបំរើការងារនៅកន្លែងផ្សេង

ខ- លោក **ជា គីមឡុង** បច្ចុប្បន្នជាប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ត្រូវព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៣ ខែ ។

**ប្រការ ២ :** ក្នុងរយៈពេលព្យួរការងារ បើគណៈកម្មការស្រាវជ្រាវករណីមិនប្រក្រតីពិនិត្យឃើញថា សាមីខ្លួនទាំងពីរពុំមានបង្កបញ្ហាខុសឆ្គងតទៅទៀតទេនោះ ទីស្តីការគណៈរដ្ឋមន្ត្រី នឹងធ្វើលិខិតជូនទៅរាជរដ្ឋាភិបាល ដើម្បីស្នើសុំការអនុញ្ញាតតែងតាំងអោយមន្ត្រីទាំងពីរ បានចូលធ្វើការតាមការកំណត់ខាងលើ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចំលងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com